**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚❃៛៛

**ក្រសួងសុខាភិបាល**

ថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការហាមឃាត់គណនីហ្វេសប៊ុកឈ្មោះ NyNy Skincare កំពុងផ្សព្វផ្សាយលក់ ផលិតផលគ្រឿងសម្អាងគ្មានចុះប្រវេទន៍ និងគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមជំរាបជូនដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថាៈ យោងតាមការពិនិត្យឃើញលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) រៀងរាល់ថ្ងៃមានគណនីឈ្មោះ NyNy Skincare កំពុងផ្សព្វផ្សាយលក់ផលិតផលគ្រឿងសម្អាងជាច្រើនមុខ ដែលគ្មានចុះប្រវេទន៍ គ្មានការត្រួតពិនិត្យគុណភាព និងគ្មានច្បាប់អនុញ្ញាតឲ្យផ្សព្វផ្សាយពីក្រសួងសុខាភិបាលដូចជាៈ ១ NyNy Skincare 5 DAYS ២ LATOJA ៣ BLEACHING CREAM ៤ NyNy Skincare Whitening night Cream ៥ NyNy Skincare Whitening body Lotion ៦ Strawberry White Body Bath និងផលិតផលគ្រឿងសម្អាងដទៃជាច្រើនទៀត ។

ដើម្បីជៀសវាងការខាតបង់ប្រាក់កាស និងប៉ះពាល់ដល់សុខភាព ឬអាចឈានដល់ការបាត់បង់ជីវិតរបស់អ្នកប្រើប្រាស់ទៀតនោះ ក្រសួងសុខាភិបាលសូមជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ ត្រូវបញ្ឈប់ការប្រើប្រាស់គ្រឿងសម្អាងទាំងនេះជាបន្ទាន់។ ក្រសួងសុខាភិបាលតម្រូវឲ្យម្ចាស់គណនីហ្វេសប៊ុកខាងលើនេះត្រូវបញ្ឈប់ការនាំចូល លក់ ចែកចាយ និងផ្សព្វផ្សាយផលិតផលគ្រឿងសម្អាងទាំងនេះជាបន្តទៀត ព្រមទាំងប្រមូលផលិតផលខាងលើនេះមកវិញដើម្បីកំទេចចោល ។

ក្រសួងសុខាភិបាលនឹងមានវិធានការតឹងរ៉ឹងទៅតាមផ្លូវច្បាប់ចំពោះគណនីហ្វេសប៊ុកឈ្មោះ NyNy Skincare ដែលបាននាំចូល លក់ ចែកចាយ និងផ្សព្វផ្សាយផលិតផលគ្រឿងសម្អាងខាងលើនេះទៅតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថជាធរមាន។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋបានជួបប្រទះឃើញជនណាកំពុងលក់ផលិតផលគ្រឿងសម្អាងខាងលើនេះ សូមបងប្អូនប្រញាប់ផ្តល់ព័ត៌មាន ឬត្រូវការព័ត៌មានបន្ថែមពីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទៈ០១១ ៥៧៤ ៧៨៧,០១២ ៩៨៣ ៣៣៤,០១២ ៥៦២ ៤២៦,០១៧ ៨៦៦ ៧៦០។

សូមភ្ជាប់មកជាមួយនូវរូបភាពគណនីហ្វេសប៊ុកឈ្មោះ NyNy Skincare និងផលិតផលគ្រឿងសម្អាងខុសច្បាប់ ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# ឈ្មោះគណនីហ្វេសប៊ុក NyNy Skincare កំពុងផ្សព្វផ្សាយលក់ផលិតផល គ្រឿងសម្អាង គ្មានចុះប្រវេទន៍ និងគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល




## សូមបងប្អូនបញ្ឈប់ការប្រើប្រាស់ជាបន្ទាន់ប្រយ័ត្ន ប្រតិកម្មស្បែករហូតដល់មានគ្រោះថ្នាក់ដល់ជីវិត



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# ឈ្មោះគណនីហ្វេសប៊ុក NyNy Skincare កំពុងផ្សព្វផ្សាយលក់ផលិតផល គ្រឿងសម្អាង គ្មានចុះប្រទេទន៍ និងគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល










## សូមបងប្អូនបញ្ឈប់ការប្រើប្រាស់ជាបន្ទាន់ប្រយ័ត្ន មានគ្រោះថ្នាក់ដល់ជីវិត




ទីស្ដីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្ដេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨២ ៩០៩


៧